# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ០៦៤ ប្រក. កសក

# ប្រកាស

**ស្តីពី**

**ការដាក់ឱ្យប្រើប្រាស់គំរូពាក្យសុំ និង**

**លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មសម្ភារៈកសិកម្ម**

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់. ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីបមាណី និង ការគ្រប់គ្រងសម្ភារៈកសិកម្ម
- បានឃើញប្រកាសលេខ ៣៥៦ ប្រក.កសក.បុ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននីតិកម្មកសិកម្ម
- បានឃើញសារាចរណែនាំការអនុវត្តអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ១៩៩៨ លេខ ៣៤៥ សរណន.កសក ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០២
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## ស ម្រេ ច

**ប្រការ ១** : អនុញ្ញាតឱ្យនាយកដ្ឋាននីតិកម្មកសិកម្មប្រើប្រាស់គំរូពាក្យសុំ និង លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មសម្ភារៈកសិកម្ម ដូចមានភ្ជាប់ជាឧបសម្ព័ន្ធស្រាប់ ។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd Sangkat Tonle Basak Khan Chamkarmon . Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១/២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23-217 320

**ប្រការ ២ :** អគ្គនាយកក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម និង គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ ២០០៣

រដ្ឋមន្ត្រី

ជ័ន្ទ សារុន

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងផែនការ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទខេត្ត ក្រុង
- ដូចប្រការ ២
- ឯកសារ- កាលប្បវត្តិ